# តើអ្វីជាគោលបំណងនៃព្រះសំរាប់ផែនដី ?

*ហេតុអ្វីក៏ព្រះយេហូវ៉ាបានបង្កើតផែនដី? (១, ២)*

*ហេតុអ្វីក៏ផែនដីឥឡូវនេះមិនមែនជាសួនមនោរម្យ? (៣)*

*តើអ្វីនឹងកើតឡើងដល់មនុស្សអាក្រក់? (៤)*

*នៅអនាគត តើព្រះយេស៊ូនឹងធ្វើអ្វីសំរាប់មនុស្សឈឺ? មនុស្សចាស់ជរា? មនុស្សស្លាប់? (៥, ៦)*

*ដើម្បីឲ្យបានចំណែកនៃពរអនាគតនេះ តើអ្នកត្រូវតែធ្វើយ៉ាងណា? (៧)*



***សួនមនោរម្យដែលបានបាត់បង់ទៅ***

១. ព្រះយេហូវ៉ាបានបង្កើតផែនដីនេះមក ដើម្បីឲ្យមនុស្សរស់នៅដោយសប្បាយជារៀងរហូត ។ ទ្រង់ចង់ឲ្យផែនដីរមែងពោរពេញទៅដោយមនុស្សសុចរិតដ៏សប្បាយចិត្តរស់នៅជានិច្ច ។ (ទំនុកដំកើង ១១៥:១៦; អេសាយ ៤៥:១៨) ផែនដីគឺមិនត្រូវនឹងបំផ្លាញចោលទៅឡើយ គឺនឹងនៅគង់វង់ជាប់ជារៀងរហូត ។—ទំនុកដំកើង ១០៤:៥; សាស្ដា ១:៤

២. មុនពេលព្រះបានបង្កើតមនុស្ស ទ្រង់បានជ្រើសរើសយកមួយចំណែកតូចនៃផែនដី ហើយបានធ្វើជាសួនមនោរម្យមួយដ៏ស្រស់ស្អាត ។ ទ្រង់ហៅវាថាសួនច្បារអេដែន ។ គឺនៅទីនេះហើយដែលទ្រង់បានដាក់បុរសនិងស្ដ្រីដំបូង គឺអ័ដាមនិងអេវ៉ាឲ្យរស់នៅ ។ ព្រះមានបន្ទូលឲ្យពួកគេបង្កើតកូនបំពេញផែនដីទាំងមូល ។ បន្ដិចម្ដងៗ ពួកគេនឹងធ្វើផែនដីទាំងមូលឲ្យទៅជាសួនមនោរម្យ ។—លោកុប្បត្តិ ១:២៨; ២:៨, ១៥

៣. អ័ដាមនិងអេវ៉ាបានប្រព្រឹត្តអំពើបាបដោយល្មើសច្បាប់នៃព្រះដោយចេតនា ។ ដូច្នេះព្រះយេហូវ៉ាបណ្ដេញពួកគេចេញពីសួនច្បារអេដែន ។ សួនមនោរម្យក៏ត្រូវបាត់បង់ទៅ ។ (លោកុប្បត្តិ ៣:១-៦, ២៣) ប៉ុន្តែព្រះយេហូវ៉ាមិនបានភ្លេចឡើយនូវគោលបំណងនៃទ្រង់សំរាប់ផែនដីនេះ ។ ព្រះអង្គសន្យាថានឹងធ្វើផែនដីឲ្យក្លាយទៅជាសួនមនោរម្យជាមិនខាន ដែលមនុស្សនឹងរស់នៅជារៀងរហូត ។ តើព្រះអង្គនឹងធ្វើការនេះដូចម្ដេច ?—ទំនុកដំកើង ៣៧:២៩

៤. មុននឹងផែនដីនេះអាចក្លាយជាសួនមនោរម្យបាន មនុស្សអាក្រក់ត្រូវតែដកចេញសិន ។ (ទំនុកដំកើង ៣៧:៣៨) ការនេះនឹងកើតឡើងនៅអើម៉ាគេដូន ដែលជាសង្គ្រាមរបស់ព្រះដើម្បីបញ្ចប់អំពើអាក្រក់ជួជាតិ ។ បន្ទាប់មក សាតាំងនឹងត្រូវឃុំទុកចោលអស់រយៈ១.០០០ឆ្នាំ ។ នេះបានសេចក្ដីថាឥតមានសល់មនុស្សអាក្រក់មកបំផ្លិចបំផ្លាញផែនដីទៀតឡើយ ។ គឺមានតែរាស្ដ្រនៃព្រះប៉ុណ្ណោះទេដែលរស់រានមានជីវិត ។—វិវរណៈ ១៦:១៤, ១៦; ២០:១-៣

៥. រួចមកព្រះយេស៊ូគ្រីស្ទនឹងគ្រប់គ្រងជាព្រះមហាក្សត្រទៅលើផែនដីនេះក្នុងរយៈ១.០០០ឆ្នាំ ។ (វិវរណៈ ២០:៦) ទ្រង់នឹងដកយកបាបបន្តិចម្តងៗចោលចេញពីចិត្តគំនិតនិងរូបកាយយើង ។ យើងនឹងក្លាយទៅជាមនុស្សគ្រប់លក្ខណ៍ដូចអ័ដាមនិងអេវ៉ាអញ្ចឹង មុនពេលដែលពួកគេបានប្រព្រឹត្តអំពើបាប ។ រួចមកនឹងលែងមានជម្ងឺឈឺថ្កាត់ ជរាភាព និងសេចក្តីស្លាប់ទៀតហើយ ។ មនុស្សឈឺនឹងបានជាសះស្បើយ ហើយមនុស្សចាស់ជរានឹងក្លាយទៅជាក្មេងវិញ ។—យ៉ូប ៣៣:២៥; អេសាយ ៣៣:២៤; វិវរណៈ ២១:៣, ៤

៦. ក្នុងគ្រាសោយរាជ្យរយៈមួយពាន់ឆ្នាំរបស់ព្រះយេស៊ូ ពួកមនុស្សស្មោះត្រង់នឹងរៀបចំកែប្រែផែនដីទាំងមូលឲ្យទៅជាសួនមនោរម្យ ។ (លូកា ២៣:៤៣) ហើយឯពួកអ្នកស្លាប់រាប់លាននាក់នឹងត្រូវប្រោសឲ្យមានជីវិតរស់ឡើងជាមនុស្សវិញនៅលើផែនដី ។ (កិច្ចការ ២៤:១៥) បើពួកគេប្រព្រឹត្តអ្វីដែលព្រះទ្រង់តម្រូវពីពួកគេ នោះពួកគេនឹងមានជីវិតរស់នៅតទៅជារៀងរហូតនៅលើផែនដី ។ បើមិនដូច្នេះទេ ពួកគេនឹងត្រូវវិនាសសាបសូន្យអស់កល្បជានិច្ច ។—យ៉ូហាន ៥:២៨, ២៩; វិវរណៈ ២០:១១-១៥

៧. ដូច្នេះ គោលបំណងដើមរបស់ព្រះសំរាប់ផែនដីនឹងបានសម្រេច ។ តើអ្នកចង់ទទួលចំណែកនៃពរអនាគតទាំងនេះឬទេ? បើចង់បាន អ្នកត្រូវតែបន្តរៀនសូត្រអំពីព្រះយេហូវ៉ា ហើយនិងប្រព្រឹត្តតាមសេចក្តីតម្រូវនៃព្រះអង្គជានិច្ចតទៅ ។ ការចូលរួមក្នុងកិច្ចប្រជុំនៅសាលព្រះរាជាណាចក្រនៃស្មរបន្ទាល់ព្រះយេហូវ៉ានាតំបន់អ្នក នោះនឹងជួយអ្នកឲ្យធ្វើយ៉ាងនេះបាន ។—អេសាយ ១១:៩; ហេព្រើរ ១០:២៤, ២៥



***ក្រោយពេលសង្គ្រាមអើម៉ាគេដូន ផែនដីនឹងត្រូវរៀបចំធ្វើឲ្យទៅជាសួនមនោរម្យ***

